LONGBEACH COMMUNITY DEVELOPMENT

សេចក្តីជូនដំណឹងជាសាធារណៈ

សេចក្តីជូនដំណឹងអំពីឯកសារដែលមានផ្តល់ជូនជាសាធារណៈ

រយៈពេលផ្តល់មតិជាសាធារណៈ 15 ថ្ងៃសម្រាប់ការពិនិត្យមើលសេចក្តីព្រាងនៃរបាយការណ៍ស្តីពីលទ្ធផលការងារ និងរង្វាយតម្លៃប្រចាំឆ្នាំរួមបញ្ចូលគ្នា (CAPER) ឆ្នាំ 2024-2025 របស់សាលាក្រុង Long Beach អំពីសកម្មភាព និងកម្មវិធីដែលទទួលថវិកាពីកញ្ចប់ថវិកាជំនួយអភិវឌ្ឍន៍សហគមន៍ (CDBG) របស់ក្រសួងគ្រប់គ្រងលំនៅឋាន និងអភិវឌ្ឍន៍ទីក្រុង (HUD) នៃសហរដ្ឋអាមេរិក, កម្មវិធីភាពជាដៃគូវិនិយោគ HOME (HOME) និងថវិកាជំនួយសម្រាប់ដំណោះស្រាយគ្រោះអាសន្ន (ESG) នឹងធ្វើឡើងចាប់ពីថ្ងៃទី 2 ខែធ្នូ ឆ្នាំ 2025 ដល់ថ្ងៃទី 17 ខែធ្នូ ឆ្នាំ 2025។ របាយការណ៍ CAPER វាយតម្លៃអំពីវឌ្ឍនភាព និងប្រសិទ្ធភាពនៃលទ្ធផលការងាររបស់សាលាក្រុងក្នុងអំឡុងឆ្នាំសារពើពន្ធ 2023-2024 នៅក្នុងសមិទ្ធផលនៃយុទ្ធសាស្ត្រ គោលដៅ និងអាទិភាពជារួមដែលបានរៀបរាប់នៅក្នុង FY 2023-2027 Consolidated Plan (ផែនការរួមបញ្ចូលគ្នាក្នុងឆ្នាំសារពើពន្ធ 2023-2027)។ សាលាក្រុងនឹងដាក់បញ្ជូនរបាយការណ៍នេះទៅ HUD មុនថ្ងៃទី 30 ខែធ្នូ 2025។

សេចក្តីព្រាងនៃរបាយការណ៍នេះអាចទាញយកពីផ្នែក "បន្តទទួលព័ត៌មាន៖ ព័ត៌មានថ្មីបំផុត (Stay Informed: Latest News)" នៃទំព័រដើមលើគេហទំព័ររបស់ក្រសួងអភិវឌ្ឍន៍សហគមន៍ (Community Development Department) នៃសាលាក្រុង Long Beach តាមរយៈ: longbeach.gov/lbcd, ទៅទីតាំងដោយផ្ទាល់នៅ 411 W. Ocean Blvd., Long Beach, CA 90802 ឬទាក់ទងទៅអ្នកស្រី Elizabeth Weithers តាមអ៊ីមែល Elizabeth.Weithers@longbeach.gov ឬតាមទូរសព្ទលេខ (562) 570-6912។

អ្នករស់នៅដែលចង់ផ្តល់មតិជាសំណេរត្រូវតែផ្តល់ត្រឹមថ្ងៃទី 17 ខែធ្នូ ឆ្នាំ 2025។ មតិនានាគួរតែផ្ញើទៅអ្នកស្រី Elizabeth Weithers នៅ Community Development Department, 411 West Ocean Boulevard, Third Floor, Long Beach, California 90802។ អ៊ីមែល: Elizabeth.Weithers@longbeach.gov។

សាលាក្រុង Long Beach មានបំណងផ្តល់ការសម្របសម្រួលសមស្របដោយយោងតាមច្បាប់ស្តីពីជនជាតិអាមេរិកដែលមានពិការភាព (ADA) ឆ្នាំ 1990។ ប្រសិនបើត្រូវការឱ្យមានការសម្របសម្រួលពិសេស ឬស្នើសុំឯកសារបកប្រែ សូមហៅទូរសព្ទទៅអ្នកស្រី Elizabeth Weithers តាមលេខ (562) 570-6912 យ៉ាងហោចណាស់ 48 ម៉ោងមុនពេលបិទបញ្ចប់រយៈពេលផ្តល់មតិជាសាធារណៈនេះ។ សម្រាប់បុគ្គលដែលមានពិការភាពទាក់ទងនឹងការស្តាប់ ឬការនិយាយ សូមហៅទូរសព្ទទៅលេខ 711 ដើម្បីភ្ជាប់ជាមួយសេវាកម្មបញ្ជូនបន្តទូរគមនាគមន៍។

ដើម្បីស្នើសុំព័ត៌មាននេះជាទម្រង់ផ្សេង ឬស្នើសុំការសម្របសម្រួលសម្រួល សូមទាក់ទងទៅក្រសួងអភិវឌ្ឍន៍សហគមន៍តាមរយៈ: longbeach.gov/lbcd និង 562.570.3807។ សូមស្នើសុំដោយទុកពេលឱ្យយើងយ៉ាងតិចបីថ្ងៃនៃថ្ងៃធ្វើការ ដើម្បីធានាថាមានការផ្តល់ជូន។
យើងនឹងព្យាយាមបំពេញតាមការស្នើសុំឱ្យសម្របសម្រួលចំពោះការទុកពេលខ្លីជាងនេះ។